## ក្របខ័ណ្ឌពង្រឹងសមាហរណកម្មនៅកម្ពុជា
## យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ឆ្នាំ ២០១៤-២០១៨
## ពិធីប្រកាសជាផ្លូវការ

-----------------------------------

សុន្ទរកថាដោយលោកស្រី ក្លែរ វ៉ាន់ ឌ័រ វ៉ារ៉េន

អ្នកសម្របសម្រួលអ.ស.ប និងតំណាងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ

នៅព្រះរាជាណាចក្រកម្ពុជា

**វិមានសន្តិភាព ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤**

*សូមគោរព៖*

*- សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា*

*- ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី (រង់ចាំការបញ្ជាក់នៅថ្ងៃប្រកាស)*

*- បណ្ឌិត រ៉ាតណាការ អាឌីការី នាយកប្រតិបត្តិនៃលេខាធិការដ្ឋានប្រតិបត្តិកម្មវិធីពង្រឹងក្របខ័ណ្ឌសមាហរណកម្ម (EIF)*

*- លោក អេរិក ស៊ីដវិក នាយកធនាគារអភិវឌ្ឍន៍អាស៊ី និងអ្នកសម្របសម្រួលម្ចាស់ជំនួយកម្មវិធី EIF សម្រាប់កម្ពុជា*

*- ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយស លោក លោកស្រីជាទីគោរព!*

### សេចក្តីផ្តើម

ការជួបជុំគ្នារបស់យើងនាថ្ងៃនេះគឺជាសក្ខីភាពនៃការប្តេជ្ញារបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបញ្ជ្រាបពាណិជ្ជកម្មទៅក្នុងការអភិវឌ្ឍជាតិ និងក្នុងការប្រើប្រាស់ពាណិជ្ជកម្មជាចលករសម្រាប់បង្កើនសំទុះនៃការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍមនុស្ស។ សូមអនុញ្ញាតឲ្យខ្ញុំអបអរសាទរចំពោះការយកចិត្តទុកដាក់របស់រដ្ឋាភិបាលចំពោះការអភិវឌ្ឍមនុស្សដោយចីរភាពនៅក្នុងយុទ្ធសាស្ត្រពាណិជ្ជកម្ម ដែលរួមទាំង ការប្រឈមថ្មីៗនៃការប៉ះពាល់បរិស្ថាន។ ក្នុងន័យនេះ អង្គការសហប្រជាជាតិនៅកម្ពុជា មានសេចក្តីរីករាយដែលបានចូលរួមនៅក្នុងពិធីប្រកាសជាផ្លូវការយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា សម្រាប់ឆ្នាំ ២០១៤-២០១៨ និងផែនទីបង្ហាញផ្លូវដែលភ្ជាប់ជាមួយ។

### ពាណិជ្ជកម្ម និងកម្ពុជា

បច្ចុប្បន្ននេះ ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន កំពុងប្រឹងប្រែងពង្រឹងភាពប្រកួតប្រជែង ជម្រុញសមាហរណកម្មក្នុងតំបន់ និងធ្វើពិពិធកម្មការនាំចេញរបស់ខ្លួន។ កម្ពុជាក៏ដូច្នោះដែរ។ ការបញ្ជ្រាបពាណិជ្ជកម្មទៅក្នុងផែនការអភិវឌ្ឍន៍ជាតិក៏មានសារៈសំខាន់ផងដែរនៅក្នុងការសម្រេចបាននូវការប៉ងប្រាថ្នាទាំងនេះ។

អ.ស.ប បាន និងនៅបន្តកៀងគរការគាំទ្រសម្រាប់ពាណិជ្ជកម្មនៅកម្ពុជា តាមវិធីជាច្រើនៈ តាមរយៈការផ្តល់ជំនាញបច្ចេកទេសសម្រាប់ការកសាងគោលនយោបាយ ការកសាងសមត្ថភាព ការសម្រួលឲ្យមានភាពជាដៃគូ និងការបង្កើតប្រព័ន្ធ និងយុទ្ធសាស្ត្រនានាដែលបង្កើតជាស្ពានផ្សារភ្ជាប់រវាងប្រជាជនកម្ពុជា និងទីផ្សារពិភពលោក។ ជាក់ស្តែង មុនពេលទទួលបានការសម្រេចពីក្រសួងពាណិជ្ជកម្មឲ្យចូលរួមក្នុងការរៀបចំបច្ចុប្បន្នកម្មយុទ្ធសាស្ត្រ DTIS កម្មវិធីអភិវឌ្ឍន៍ប្រជាជាតិ UNDP នៅកម្ពុជាបានផ្តល់ការគាំទ្រខាងគោលនយោបាយ និងបច្ចេកទេសសម្រាប់ការរៀបចំអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade SWAp) និងពង្រឹងសមត្ថភាពផ្គត់ផ្គង់នៃវិស័យជាក់លាក់នានា។ UNIDO គាំទ្រដល់ការអភិវឌ្ឍវិស័យផលផល និងក្នុងការធ្វើឲ្យមានភាពប្រសើរដល់ស្តង់ដារខ្នាតទំហំ ការធ្វើតេស្ត និងគុណភាព ចំណែកមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ (ITC) នាំយកជំនួយគាំទ្រដល់សហគមន៍ងាយរងគ្រោះនានា ដើម្បីលើកកំពស់គុណភាពផលិតផលសូត្ររបស់កម្ពុជា។ សន្និសីទសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍ ឬ UNCTAD បានផ្តល់ការគាំទ្រដល់ការអនុវត្ត និងការដាក់ពង្រាយប្រព័ន្ធទំនើបសម្រាប់ទិន្នន័យគយ ក៏ដូចជា បានផ្តល់កិច្ចសហប្រតិបត្តិការបច្ចេកទេសដល់ប្រទេសកម្ពុជានៅមុន និងនៅក្រោយចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកផងដែរ។ UNCTAD បានខ្នះខ្នែងជួយកម្ពុជាឲ្យទទួលផលពីប្រព័ន្ធអនុគ្រោះទូទៅ ក៏ដូចជា ក្នុងការធ្វើទំនើបកម្មយន្តការវិធានប្រភពដើមទំនិញផងដែរ។ ក្នុងនាមជាកិច្ចប្រឹងប្រែងថ្មីមួយ UNDP កំពុងគាំទ្រដល់វិស័យដំឡូងមី តាមរយៈភាពជាដៃគូជាមួយកម្មវិធីពង្រឹងក្របខ័ណ្ឌសមាហរណកម្ម (EIF) និងក្រសួងពាណិជ្ជកម្មនៃសាធារណរដ្ឋប្រជាមានិតចិន។

កិច្ចប្រឹងប្រែងទាំងនេះបាន និងកំពុងបន្តអនុវត្តជាមួយការប្តេជ្ញាស្នូលរបស់ក្រុមស្ថាប័នអ.ស.ប ប្រចាំនៅកម្ពុជា "... ដើម្បីគាំទ្រដល់កិច្ចប្រឹងប្រែងទាំងនេះរបស់រាជរដ្ឋាភិបាលកម្ពុជា និងប្រជាជនកម្ពុជា សំដៅលើកកំពស់ជីវភាពរបស់ប្រជាជនទាំងអស់ ដែលរស់នៅកម្ពុជា ជាពិសេស អ្នកដែលមិនបានទទួលការគិតគូរ និងងាយរងគ្រោះ។"

ខ្ញុំសូមគូសបញ្ជាក់ពីចំណងទាក់ទងដ៏សំខាន់ ដែលបានសម្រេចបានកន្លងមករវាងពាណិជ្ជកម្ម និងការអភិវឌ្ឍមនុស្សនៅកម្ពុជា និងសារៈសំខាន់នៃសមភាព ចីរភាព និងការទទួលផលទាំងអស់គ្នានៅក្នុងកំណើនដែលទាក់ទងនឹងពាណិជ្ជកម្ម។ ក្នុងន័យនេះ យុទ្ធសាស្ត្រ CTIS ផ្តល់នូវការណែនាំយុទ្ធសាស្ត្រដ៏ប្រសើរមួយ តែទោះជាយ៉ាងណាក៏ដោយ ក៏នៅមានភាពចាំបាច់ឲ្យមានការស្រាវជ្រាវ និងកិច្ចប្រឹងប្រែងច្រើនថែមទៀត ដើម្បីស្វែងយល់បានកាន់តែប្រសើរឡើង អំពីថាតើវិស័យពាណិជ្ជកម្មជាអាទិភាព អាចជួយលើកស្ទួយប្រជាជនឲ្យចាកចេញពីភាពក្រីក្របានដូចម្តេចខ្លះ។ នៅក្នុងវិស័យទាំងនេះ ឱកាសការងារនិងប្រាក់ចំណូលមិនទៀងទាត់ បានបង្ហាញឲ្យឃើញថា វាមិនអាចនាំទៅរកការអភិវឌ្ឍមនុស្សដោយចីរភាពបានឡើយ។ ជាចាំបាច់ ត្រូវមានការយកចិត្តទុកដាក់ថែមទៀតលើគោលនយោបាយ ដើម្បីបម្លែងយុទ្ធសាស្ត្រពាណិជ្ជកម្មដ៏ល្អមួយនេះ ឲ្យទៅជាលទ្ធផលដែលអាចផ្តល់ផលប្រកបដោយនិរន្តរភាពដល់ពលរដ្ឋដែលតាមធម្មតាមិនសូវបានទទួលការគិតគូរ និងងាយរងគ្រោះបំផុត។ វាជាការលើកទឹកចិត្តមួយដែលយើងបានឃើញកំណែទម្រង់បច្ចុប្បន្ននេះ ដែលរាជរដ្ឋាភិបាលកំពុងអនុវត្តតាមរយៈក្រសួងពាណិជ្ជកម្ម ដើម្បីធ្វើឲ្យនីតិវិធីនៃការនាំចេញមានលក្ខណៈងាយស្រួល និងក្នុងការបង្កើតបន្ថែមនូវបរិយាកាសអំណោយផលសម្រាប់ពង្រីកកិច្ចសម្រួលដល់ពាណិជ្ជកម្ម។ អ.ស.ប ត្រៀមខ្លួនជាស្រេច

ប្រសិនបើកម្មករត្រូវធ្វើវិនិយោគលើជំនាញរបស់ខ្លួន ទីផ្សារការងារត្រូវផ្ដល់ការលើកទឹកចិត្តសម្រាប់កម្មករដើម្បីអាចធ្វើការវិនិយោគបែបនេះបាន។

**ក្នុងន័យនេះ វិស័យទីបីនៃកិច្ចសហការដែលអាចអនុវត្តបានគឺ ការបង្កើតយន្តការនានាសម្រាប់ការចរចារួមគ្នាលើកិច្ចព្រមព្រៀងនានា ឬ "CBAs"** ។ សមាសភាគគួរឲ្យស្វាគមន៍មួយក្នុងយុទ្ធសាស្ត្រ CTIS គឺការផ្ដល់អាទិភាពរបស់វាចំពោះភាពចាំបាច់ដើម្បីស្វែងយល់ពីយន្តការនានាសម្រាប់ការចរចារួមគ្នាលើកិច្ចព្រមព្រៀងនានា CBAs ។ ក្រៅពីជួយសម្រួលឲ្យមានសន្តិភាពក្នុងឧស្សាហកម្ម CBAs ផ្ដល់ជាយន្តការដើម្បីធានាឲ្យមានការបន្ស៊ីគ្នារវាងប្រាក់កម្រៃ និងផលិតភាពការងារផងដែរ។ ប្រការនេះនឹងអាចបង្កើតជាការលើកទឹកចិត្តខាងសេដ្ឋកិច្ចសម្រាប់កម្មករដើម្បីធ្វើការវិនិយោគលើការកែលម្អជំនាញ ទន្ទឹមនឹងការធានាថា ជំនួញនានានៅតែផ្ដល់ផលចំណេញ។

ប្រព័ន្ធអ.ស.ប នឹងបន្តធ្វើការយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធានាថាចំណងទាក់ទងវិជ្ជមានរវាងពាណិជ្ជកម្ម និងការអភិវឌ្ឍមនុស្សនៅតែរឹងមាំជាដរាប។ យើងអំពាវនាវដល់ដៃគូអភិវឌ្ឍន៍របស់កម្ពុជាឲ្យបន្តផ្ដល់ការគាំទ្រដល់កិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដើម្បីសម្រេចគោលដៅសេដ្ឋកិច្ច និងអភិវឌ្ឍន៍ ដែលកម្ពុជាបានលាតត្រដាងនៅក្នុងយុទ្ធសាស្ត្រចតុកោណជំហានទី ៣។

នៅទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណរាជរដ្ឋាភិបាលកម្ពុជា និង ជាពិសេសក្រសួងពាណិជ្ជកម្ម ចំពោះការដឹកនាំដ៏មុតមាំក្នុងការរៀបចំ និងការអនុវត្ត យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជាឆ្នាំ២០១៤-២០១៨។ ខ្ញុំរំពឹងថានឹងឃើញការរីកចម្រើនគួរឲ្យចាប់អារម្មណ៍នៅក្នុងបណ្ដាឆ្នាំខាងមុខនេះ នៅពេលដែលយើងរួបរួមគ្នាជាដៃគូដើម្បីបម្លែងយុទ្ធសាស្ត្រពាណិជ្ជកម្មដ៏ប្រសើរមួយនេះឲ្យទៅជាលទ្ធផល ដែលផ្ដល់ជាប្រយោជន៍ប្រកបដោយនិរន្តរភាពសម្រាប់ជនកម្ពុជាគ្រប់រូប។

សូមអរគុណ!